ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែឧសភា ឆ្នាំ២០១៩

នៅក្នុងខែឧសភា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក

-អញ្ជើញជូន និងទទួលព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតស្តេចយាងបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញជូនព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតស្តេចយាងចូលរួមក្នុងពិធីប្រារព្ធខួប២៥ឆ្នាំ នៃសកម្មភាពគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិរក្សតំបន់អង្គរ នៅសាធារណរដ្ឋបារាំង

-អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៦៦យាងចូល៦៧ព្រះវស្សាថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះមហាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង

-អញ្ជើញជាគណៈអធិបតីក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែ ភូមិត្រពាំងអង្គ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ

-អនុញ្ញាតជូនឯកឧត្តម **ខាត់ហ្កា ប្រាសាទសាម៉ាអូលី** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ និងគណៈប្រតិភូចូលជួបសម្តែងការគួរសម ក្នុងឱកាសដែលឯកឧត្តមបានដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អនុញ្ញាតជូនលោកជំទាវ **អោង សានស៊ូជី** (Aung SanSuukyi) ទីប្រឹក្សារដ្ឋ នៃសាធារណរដ្ឋមីយ៉ាន់ម៉ា ចូលជួបសម្តែងការគួរសម និងសវនាការ

-អនុញ្ញាតឱ្យឯកឧត្តម Christopher Baltazar MONTERO ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋហ្វីលីពីន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

-អញ្ជើញចូលរួមអបអរសាទរខួបលើកទី១៥៦ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម៨ឧសភា ក្រោមប្រធានបទ "ខ្ញុំស្រលាញ់កាកបាទក្រហមកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រម្ពុជា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងការប្រកួតកីឡាវាយកូនគោល ពានរង្វាន់**សម្តេចក្រឡាហោម ស ខេង** នៅទីលានវាយកូនគោលហ្គ្រែនភ្នំពេញ

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យវិសាខបូជា នៅឧបដ្ឋានសាលាខាងក្រោម ដែលស្ថិតនៅខាងកើតព្រះមហាសក្យមុនីចេតិយ៍ នៅភ្នំព្រះរាជទ្រព្យ(ឧត្តុង្គ) ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញសាកសួរសុខទុក្ខលោកជំទាវ **ផ្សេក ភីរុណ** អតីតប្រធានកាកបាទក្រហម ដែលមកដល់បច្ចុប្បន្ននេះលោកជំទាវមានជន្មាយុ៩៩ឆ្នាំនិងកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ

-អញ្ជើញសម្ពោធសមិទ្ធផល និងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅខណ្ឌជង្កោ និងមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ មន្ត្រី កងកម្លាំង និងប្រជាពលរដ្ឋ ដែលបានមកទំនាក់ទំនងការងារសេវាសាធារណៈ នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ **ឡេ ដឹកអាញ់** (Le Duc Anh) អតីតប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមបុណ្យសពប្រជាពលរដ្ឋក្រីក្រ ស្ថិតនៅផ្ទះលេខ២២៤$CE_0$ ផ្លូវលេខ ២២២ ភូមិ៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់។

**១.២-ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំស្តីពី ការរៀបចំវេទិកាភូមិភាគទី១ ក្រោមប្រធានបទការរៀបចំការអនុវត្តថវិកាថ្នាក់ក្រោមជាតិ រាជធានី ខណ្ឌ សង្កាត់ ក្នុងការអភិវឌ្ឍមូលដ្ឋានដើម្បីបំពេញសេវាជូនប្រជាពលរដ្ឋប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព

-អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋចំណុះជើងវត្ត និងព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត និងចុះពិនិត្យការដ្ឋានសាងសង់សមិទ្ធផលនានានៅក្នុងវត្តទេពនីមិត្ត ហៅវត្តអញ្ចោញ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ **ឡេ ដឹកអាញ់** (Le Duc Anh) អតីតប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន២៤ច្បាប់ៗ

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល និងទស្សនាពិព័រណ៍ផលិតផលកសិកម្មសិប្បកម្មក្នុងស្រុក ក្រោមព្រះរាជាអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ-កម្ពុជា នៅទីព្រះស្រែ ភូមិត្រពាំងអង្គ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ

-អនុញ្ញាតឱ្យគណៈប្រតិភូបក្សកុម្មុយនីស្តចិន ដឹកនាំដោយឯកឧត្តម Wang Yajum អនុរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិមជ្ឈិមបក្សកុម្មុយនីស្តចិន ចូលជួបសម្តែងការគួរសម

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល

-អញ្ជើញចូលរួមអបអរសាទរខួបលើកទី១៥៦ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម៨ឧសភា ក្រោមប្រធានបទ "ខ្ញុំស្រលាញ់កាកបាទក្រហមកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋ-មន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមឧត្តមសេនីយ៍ **ឡេ ដឹកអាញ់** (Le Duc Anh) អតីតប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញទៅសួរសុខទុក្ខឯកឧត្តម **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ដែលកំពុងពិនិត្យព្យាបាលជំងឺ នៅប្រទេសវៀតណាម

-អញ្ជើញចុះសួរសុខទុក្ខឯកឧត្តម **ឃឹម សារិទ្ធ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលកំពុងពិនិត្យ ព្យាបាលជំងឺ នៅមន្ទីរពេទ្យព្រះកេតុមាលា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន០២ច្បាប់។

**២-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែឧសភានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**២.១- មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៩ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ០៨ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៨ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន០៥ករណី

-អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងពិនិត្យការជីកស្តារស្រះទឹកទី២ និងស្រះទឹកទី៥ ស្ថិតនៅភូមិព្រៃទប់ ឃុំបឹងសាលាខាងជើង និងភូមិព្រៃកកឹក ឃុំប្រាសាទភ្នំខ្យង ស្រុកកំពង់ត្រាច ខេត្តកំពត

-អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើគម្រោងតាមដានលទ្ធផលការងារក្រោយរៀបចំកម្មវិធីជួបសំណេះសំណាល នៅខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង

-អញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការបំប៉នបន្ថែមនូវជំនាញផ្នែកជីវសុវត្ថិភាព និងការបង្កើតមុខជំនាញអាជីវកម្មផលិតកម្មលើការចិញ្ចឹមសត្វ

-អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពី ការដាក់បេក្ខភាពសភាកម្ពុជាចូលជាសមាជិកគណៈកម្មាធិការប្រតិបត្តិរបស់ IPU

-អញ្ជើញចូលរួមប្រជុំក្រុមIPU ត្រួតពិនិត្យលើរបាយការណ៍លទ្ធផលមហាសន្និបាតសហភាពអន្តរសភាលើកទី១៤០ នៅទីក្រុងDoha នៅប្រទេសកាតា

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍APF

-អញ្ជើញចូលរួមកិច្ចប្រជុំរាយការណ៍អំពីលទ្ធផលនៃការអនុវត្តនាពេលកន្លងមក និងផែនការអនុវត្តនាពេលអនាគតរបស់គណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

-អញ្ជើញចូលរួមប្រជុំស្តីពី ការរៀបចំការអនុវត្តថវិកាថ្នាក់ក្រោមជាតិ (រាជធានី ខណ្ឌ សង្កាត់)

-អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងស្តាប់របាយការណ៍អំពីលទ្ធផល នៃការប្រឡងក្របខ័ណ្ឌមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជនខេត្តកំពង់ចាម ស្តីពី ការត្រៀមរៀបចំអបអរសាទរទិវាកុមារអន្តរជាតិ០១មិថុនា ខួបលើកទី៧០ នៅខេត្តកំពង់ចាម

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង និងរាជ-ធានីភ្នំពេញចំនួន១៧៨លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិ-មនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៥លើក ។

**៣- កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ជា ដេដូ** អនុញ្ញាតឱ្យលោក **Yao Jian Jun** និងលោក **JIANG GUO RONG** តំណាងក្រុមហ៊ុនចិន (Seanghai International Teachnology Co., Ltd Cambodia)

និងអង្គការសប្បុរសធម៌មេគង្គ (Mekong Charity) ចូលជួបសម្ដែងការគួរសម និងពិភាក្សាអំពី ការវិនិយោគនៅក្នុងប្រទេសកម្ពុជា

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អនុញ្ញាតឱ្យគណៈប្រតិភូចិន ចូលជួបពិភាក្សាការងារ ដើម្បីរកដំណោះស្រាយអំពី ផលប៉ះពាល់មួយចំនួននៅតំបន់អភិវឌ្ឍន៍កែវផុសពាក់ព័ន្ធទៅនឹងការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ព្រមទាំងបានចុះហត្ថលេខាលើកិច្ចសន្យាដែលនៅសេសសល់ពុំទាន់បានដោះស្រាយ ដើម្បីផ្ដល់ឱកាសដល់ភាគីចិនក្នុងការសាងសង់ផ្លូវនេះឱ្យសម្រេចបានតាមផែនការ ។

ថ្ងៃសុក្រ ៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ